ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៣.....សហវ.~..

រាជធានីភ្នំពេញ, ថ្ងៃទី.០៧....ខែកញ្ញា.....ឆ្នាំ២០០៧

## សារាចរណែនាំបន្ថែម លើសារាចរណែនាំ

## ស្តីពី

## ការចំណាយតាមនិតិវិធីរជ្ជទេយ្យបុរេប្រទាន

## (សំរាប់ថវិកាតាមកម្មវិធី)

ក្នុងគោលបំណងអោយការអនុវត្តន៍ចំណាយតាមនិតិវិធីរជ្ជទេយ្យបុរេប្រទានរបស់ថវិកាតាមកម្មវិធីដំណើរការដោយភាពរលូននិងមានការឯកភាពគ្នាទូទាំងប្រទេសនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការកែសំរួលនូវចំណុចមួយ ចំនួននៃសារាចរណែនាំលេខ ០១៤សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការចំណាយតាមនិតិវិធីរជ្ជទេយ្យបុរេប្រទានដូចខាងក្រោម:

**<u>១-អំពីតារាងឧបសម្ព័ន្ធត្រូវបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី:</u>**

ក្នុងតារាងឧបសម្ព័ន្ធបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី ត្រូវជ្រើសរើសយកមាតិកាចំណាយតាម គណនី និងអនុគណនីនៃជំពូក **៦០ -៦១ -៦២ -៦៤ -៦៥** ដែលជាចំណាយចាំបាច់សំរាប់កិច្ចដំណើរការរដ្ឋបាល ដោយដកចេញចំពោះខ្ទង់ចំណាយទាំងឡាយ ដែលសាមីក្រសួង-ស្ថាប័ន-មន្ទីរ-អង្គភាពទុកសំរាប់ចំណាយតាម និតិវិធីទូទាត់ត្រង់។

**<u>២-អំពីទឹកប្រាក់នៃជុំបង្វិលសំរាប់រជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី:</u>**

ចំពោះទឹកប្រាក់ជុំបង្វិលសំរាប់រជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធីគឺ ត្រូវគិត១ភាគ៤នៃទឹកប្រាក់សរុបសំរាប់បង្កើតរជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី ។

**<u>៣-អំពីកិច្ចដំណើរការនៃរជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី:</u>**

ចំនួនទឹកប្រាក់សំរាប់មួយគោលការណ៍ចំណាយ (មួយប័ណ្ណចំណាយ) មិនត្រូវបានកំណត់ដូចថវិកាមិនមែនតាមកម្មវិធីនោះទេ គឺត្រូវបានធ្វើការទូទាត់ទៅតាមការជាក់ស្តែង ។

ចំពោះចំណុចទាំងឡាយផ្សេងៗទៀត ដែលមានចែងនៅក្នុងសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៦ គឺនៅតែជាធរមានដដែល ។

លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសារាចរណែនាំបន្ថែមនេះត្រូវចាត់ទុកជានិរាករណ៍ ។

ទទួលបានសារាចរណែនាំបន្ថែមនេះ សូមគ្រប់ក្រសួង-ស្ថាប័ន-មន្ទីរ-អង្គភាព និងសាលាខេត្ត-ក្រុងត្រូវគោរព អនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ។ ✓/ ✓

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង-ស្ថាប័ន-រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ